# សេចក្តីសង្ខេបនៃវេទិកាសាធារណៈថ្នាក់ជាតិ
# ស្តីពី
# "ការចូលរួមរបស់ពលរដ្ឋ ក្នុងដំណើរការនៃការកសាងផែនការថវិកា និង ការតាមដានលើចំណូល ចំណាយថវិកាសាធារណៈ ក្នុងបរិបទក្រោយកូវីដ ១៩"

ថ្ងៃព្រហស្បតិ៍ ៩ រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ត្រូវនឹង ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២២ ចាប់ពីម៉ោង ៨:០០ ដល់ម៉ោង ០៥:៣០ រសៀល
ទីកន្លែង: សណ្ឋាគារកាំបូឌីយ៉ាណា

ក្រុមការងារថវិកាដែលសម្របសម្រួលដោយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា បានរៀបចំវេទិកាសាធារណៈស្តីពី "ការចូលរួមរបស់ពលរដ្ឋ ក្នុងដំណើរការនៃការកសាងផែនការថវិកា និងការតាមដានលើចំណូលចំណាយថវិកាសាធារណៈ ក្នុងបរិបទក្រោយកូវីដ ១៩" ទាំងនៅកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ វេទិកានេះបានទទួលការអញ្ជើញចូលរួមពីអ្នកពាក់ព័ន្ធសំខាន់ៗមានដូចជា៖ តំណាងក្រសួងស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលជាង ១០ រួមមាន ៖ ព្រឹទ្ធសភា រដ្ឋសភា ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ក្រសួងមហាផ្ទៃ ក្រសួងអភិវឌ្ឍន៍ជនបទ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ក្រសួងផែនការ ក្រសួងព័ត៌មាន ក្រសួងកិច្ចការនារី អគ្គនាយកដ្ឋានពន្ធដារ ធនាគារជាតិនៃកម្ពុជា ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម អាជ្ញាធរមូលដ្ឋាន វិស័យឯកជន (សមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ទីភ្នាក់ងារអង្គការសហប្រជាជាតិ តំណាងដៃគូអភិវឌ្ឍន៍រួមមានដូចជា ប្រតិភូនៃសហភាពអឺរ៉ុប (EU) អង្គការសង្គមស៊ីវិលជាតិ អន្តរជាតិ តំណាងសាកលវិទ្យាល័យ ស្ថាប័នសិក្សាស្រាវជ្រាវ និស្សិត យុវជន សហគមន៍ជនជាតិដើមភាគតិច បងប្អូនប្រជាពលរដ្ឋ និងប្រព័ន្ធផ្សព្វផ្សាយសារព័ត៌មាន ដែលបានចូលរួមដោយផ្ទាល់ប្រមាណ ១៥០ នាក់ (ស្ត្រី ៦០នាក់) និងពី ចម្ងាយតាមប្រព័ន្ធ Zoom ប្រមាណជាង ៦០ (ហុកសិបនាក់) អ្នកទស្សនាតាមប្រព័ន្ធបណ្តាញសង្គមហ្វេសប៊ុក ចំនួន ៥ ស្ថាប័ន សរុបចំនួនប្រមាណ ២,០០០ (ពីរពាន់នាក់)។

វេទិកានេះធ្វើឡើងក្នុងគោលបំណងធំៗចំនួនបីរួមមាន៖

១) បង្កើនការយល់ដឹង និងលើកកម្ពស់ការចូលរួមរបស់សាធារណជន ទៅលើតម្លាភាព និងគណនេយ្យភាពថវិការួមទាំងដំណើរការនៃការរៀបចំផែនការថវិកា និងការអនុវត្តផែនការថវិកានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

២) ផ្តល់ឱកាសដល់អ្នកបង់ពន្ធរួមទាំងយុវជន សង្គមស៊ីវិល/អង្គការមិនមែនរដ្ឋាភិបាល បានជួបជជែកពិភាក្សាជាមួយក្រសួងពាក់ព័ន្ធ និងអ្នកធ្វើគោលនយោបាយនានា សំដៅឆ្ពោះទៅបង្កើនការចូលរួមជាសាធារណៈ នៅក្នុងវដ្តនៃដំណើរការរៀបចំផែនការថវិកានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

៣)ផ្តល់ឱកាសដល់អ្នកបង់ពន្ធរួមទាំងយុវជនសង្គមស៊ីវិល/អង្គការមិនមែនរដ្ឋាភិបាលផ្តល់នូវធាតុចូលជូនក្រសួងពាក់ព័ន្ធនិងអ្នកធ្វើគោលនយោបាយនានា សំដៅឆ្ពោះទៅធ្វើឲ្យប្រសើរឡើងនូវតម្លាភាព និង គណនេយ្យភាពថវិកាជាតិ ការបញ្ជ្រាបយេនឌ័រ គោលការណ៍បរិយាប័ន្ន និងជម្រើសផ្សេងទៀតដើម្បីលើកកម្ពស់ ប្រសិទ្ធភាពផែនការថវិកាថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ជាលទ្ធផល អ្នកចូលរួមវេទិកាទាំងអស់បានបង្ហាញនូវអំណរសាទរដោយឃើញវត្តមានពីគ្រប់តួអង្គអភិវឌ្ឍន៍ទាំងអស់ចូល រួមក្នុងការធ្វើបច្ចុប្បន្នភាព និងការពិភាក្សាប្រកបដោយស្មារតីយោគយល់ និងភាពជាដៃគូទាក់ទងនឹងប្រធានបទ។ យើងជឿជាក់យ៉ាងមុតមាំថាប្រជាពលរដ្ឋកម្ពុជានឹងមានសម្លេងនៅក្នុងរបៀបនៃការចំណាយសាធារណៈក៏ដូចជា នៅក្នុងការសម្រេចចិត្តនានា ដែលប៉ះពាល់ដល់ជីវភាពរស់នៅរបស់ពួកគេក្នុងឃុំ ស្រុក ក្រុង និងបរិស្ថានដែលពួកគេរស់នៅប្រចាំថ្ងៃ។

អង្គវេទិកានេះដំណើរការទៅដោយមានជាកិច្ចពិភាក្សាទៅលើប្រធានបទសំខាន់ៗចំនួន០៣រួមមាន៖

**១- ការចូលរួមរបស់សាធារណជនក្នុងដំណើរការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ**

**២- ការចូលរួមរបស់សាធារណជន ក្នុងដំណើរការកសាងផែនការរៀបចំថវិកា និងការ ត្រួតពិនិត្យតាមដានការអនុវត្តផែនការថវិការដ្ឋបាលថ្នាក់ក្រោមជាតិ**

**៣- ការរៀបចំថវិកាឆ្លើយតបទៅនឹងការគ្រប់គ្រងធនធានធម្មជាតិ សហគមន៍មូលដ្ឋាន ការប្រែប្រួលអាកាសធាតុ**

ក្នុងប្រធានបទនីមួយៗ យើងបានពិភាក្សាគ្នាលើបីចំណុចធំៗដូចជា៖

**១. ចំណុចវិជ្ជមាននៃយន្តការដែលមានស្រាប់ និងការអនុវត្តកន្លងមក**

**២. បញ្ហាប្រឈមមួយចំនួនដែលរាំងស្ទះដល់ដំណើរការអនុវត្តកន្លងមក**

**៣. សំណូមពរ និងអនុសាសន៍លើកទិសដៅជាអាទិភាពដែលត្រូវអនុវត្តបន្តដោយភាគីពាក់ព័ន្ធនានា**

ជាលទ្ធផល យើងទាំងអស់គ្នាសូមសម្តែងនូវអំណរសាទរចំពោះចំណុចជាវិជ្ជមាននៃយន្តការដែលមានស្រាប់ និង ការអនុវត្តកន្លងមកពាក់ព័ន្ធទៅនឹងការចូលរួមរបស់ពលរដ្ឋ ក្នុងដំណើរការរៀបចំថវិកានិងការត្រួតពិនិត្យតាមដានដែល មានចំនួនប្រមាណ៖ **៣៥** ចំណុចវិជ្ជមាន និងវឌ្ឍនភាព។ បញ្ហាប្រឈម មួយចំនួនដែលរាំងស្ទះទៅដល់គុណភាពនៃការពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តថវិកាដ៏គួរឱ្យកត់សម្គាល់ដែលបានលើកឡើង ក្នុងកិច្ចពិភាក្សានៃវេទិការួមមាន **២៣** ចំណុច និងអនុសាសន៍ចំនួន **២៣** ចំណុច។

ខាងក្រោមនេះគឺជាសេចក្តីសង្ខេបខ្លឹមសារនៃកិច្ចពិភាក្សាដែលវាគ្មិនជំនាញ និងអ្នកចូលរួមក្នុងអង្គវេទិកាបានលើកឡើង៖

## ១.១. ចំណុចវិជ្ជមាននៃយន្តការដែលមានស្រាប់ និងការចូលរួមរបស់សាធារណជនក្នុងដំណើរការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (១២ ចំណុច)៖

១.១.១ រាជរដ្ឋាភិបាលបានខិតខំក្នុងការអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គិតចាប់តាំងពីឆ្នាំ២០១៥ និងនៅតែបន្តអនុវត្តដើម្បីសម្រេចគោលដៅ ដែលបានគ្រោងទុកនៅឆ្នាំ២០២៥។

១.១.២ រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំគោលនយោបាយសំខាន់ៗនានាទាក់ទងនឹងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងតែងតែបានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពីដំណើរការរៀបចំច្បាប់ថវិកាជាតិប្រចាំឆ្នាំនីមួយៗ ទៅតាមលទ្ធភាព និងតាមការយល់ឃើញរបស់ខ្លួនអំពីភាពចាំបាច់នៃវេទិកានេះ ដោយបានសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធមាន ដូចជា៖ បណ្តា ក្រសួងស្ថាប័នរដ្ឋ វិស័យឯកជន អង្គការសង្គមស៊ីវិល និងតំណាងមកពីសាកលវិទ្យាល័យនានា។

១.១.៣ នៅក្នុងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រដ្ឋសភាជាតិបានបំពេញកាតព្វកិច្ចសំខាន់ចំនួនពីរ៖ ទី១) ការគិតគូរពីក្របខ័ណ្ឌច្បាប់តាមរយៈការសម្រេច និងអនុម័តច្បាប់ក្នុងការអនុវត្តទាក់ទងនឹងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងទី២) ការត្រួតពិនិត្យ តាមដាន ការអនុវត្តរបស់ក្រសួងស្ថាប័ន។

១.១.៤ រាជរដ្ឋាភិបាលក៏បាននិងកំពុងគិតគូពីផែនការបន្តដូចជា៖ ១) បន្តពង្រឹងការគ្រប់គ្រងរដ្ឋបាលសាធារណៈ ២) បន្តជំរុញការកសាងភាពធន់សេដ្ឋកិច្ច និងការធ្វើពិពិធកម្មសេដ្ឋកិច្ច ៣) ពន្លឿនភាពធន់នៃសង្គមដើម្បីត្រៀមខ្លួនក្នុងការទប់ស្កាត់ការរាតត្បាតនៃជំងឺផ្សេងៗនាពេលអនាគត ៤) ភាពធន់ហិរញ្ញវត្ថុ ដោយផ្តោតលើប្រព័ន្ធបច្ចេកវិទ្យា។

១.១.៥ កម្ពុជាមានក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចកម្រិតមធ្យមដែលអាចព្យាករណ៍ បានច្បាស់លាស់ ឆ្លើយតបទៅនឹងបរិការជាក់ស្តែងក្នុងបរិបទក្រោយជំងឺកូវីដ-១៩។

១.១.៦ រដ្ឋសភាមានតួនាទីក្នុងការអនុវត្តច្បាប់ដែលពាក់ព័ន្ធនឹងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងតែងតែធ្វើការទៅតាមជំនាញរបស់ខ្លួន ឧទាហរណ៍ ដូចជាការរៀបចំច្បាប់ទាក់ទងនឹងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតែងតែបានលើកយកបញ្ហារបស់ប្រជាពលរដ្ឋ និងជជែកជាមួយក្រសួងពាក់ព័ន្ធដើម្បីដោះស្រាយបញ្ហាដែលកើតមានឡើង។

១.១.៧ គណៈកម្មការទី២ នៃរដ្ឋសភាតែងតែធ្វើការតាមដានគ្រប់ដំណាក់កាល ព្រមទាំងបានអញ្ជើញតំណាងក្រសួងមកធ្វើការបកស្រាយ នៅពេលដែលមានបញ្ហាមិនប្រក្រតីណាមួយកើតឡើង។

១.១.៨ តាមរបាយការណ៍ការអង្កេតព័ត៌មានថវិកា (OPEN BUDGET SURVEY) ពិន្ទុទាក់ទងនឹងតម្លាភាពថវិកាមានការកើនឡើងដែលនេះបង្ហាញថា រដ្ឋសភាកម្ពុជាបាននិងកំពុងតែយកចិត្តទុកដាក់លើការកែទម្រង់នានា និងធានាបាននូវប្រសិទ្ធភាព និងស័ក្តសិទ្ធភាព។

១.១.៩ នៅរដ្ឋសភាមានអាជ្ញាធរសវនកម្ម តែងតែធ្វើសវនកកម្មជាប្រចាំ លើចំណូលចំណាយរបស់ក្រសួង និងមានអង្គភាពប្រឆាំងអំពើពុករលួយជាអ្នកចាត់វិធានការលើភាពមិនប្រក្រតីប្រសិនបើស្ថាប័នណាមួយបានប្រព្រឹត្តអំពើពុករលួយ។

១.១.១០ រាជរដ្ឋាភិបាលកម្ពុជាដែលមានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាសេនាធិការ តែងតែបានរៀបចំ និងបង្ហាញថវិកាសង្ខេបនៅលើគេហទំព័រនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលបានបង្កលក្ខណៈងាយស្រួលដល់សាធារណៈជនក្នុងការតាមដានពីការវិវឌ្ឍនៃការរៀបចំច្បាប់ថវិកាជាតិ។

១.១.១១ វឌ្ឍនភាពនៃការអនុវត្តការកែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅតែមានដំណើរការល្អ បើទោះបីជាមានវិបត្តិនៃជំងឺកូវីដ-១៩ក៏ដោយ។ ក្នុងនោះផងដែរ ក្នុងអំឡុងពេលនៃការរាតត្បាតជំងឺកូវីដ-១៩ រាជរដ្ឋាភិបាលកម្ពុជា បានគិតគូដល់ការផ្តល់សាច់ប្រាក់ដល់ប្រជាពលរដ្ឋ ដែលរងប៉ះពាល់ដោយជំងឺកូវីដ-១៩។

១.១.១២ កម្ពុជាមានក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ។

## ១.២ បញ្ហាប្រឈមមួយចំនួនដែលរាំងស្ទះការចូលរួមរបស់សាធារណជន ក្នុងដំណើរការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (៧ ចំណុច)

១.២.១ តាមរបាយការណ៍អង្កេតព័ត៌មានថវិកា (OBS) ឆ្នាំ២០១៩ បានបង្ហាញថាកម្ពុជាទទួលបានពិន្ទុតែ ៦ លើ ១០០ ដែលនេះបង្ហាញថាការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើការរៀបចំថវិកានៅមានតិចតួចនៅឡើយ។

១.២.២ ពិន្ទុនៃការចូលរួមនៅក្នុងរបាយការណ៍ អង្កេតព័ត៌មានថវិកា (OBS) មានការធ្លាក់ចុះដោយសារតែ ក្នុងបរិបទនៃជំងឺកូវីដ-១៩។

១.២.៣ ថវិកាសង្ខេបដែលបានដាក់នៅគេហទំព័រនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅតែមានលក្ខណៈស្មុគស្មាញនិងពិបាកយល់។

១.២.៤ ទម្រង់ថវិកាមានលក្ខណៈស្មុគស្មាញ និងមានលក្ខណៈបច្ចេកទេសពេកធ្វើឱ្យប្រជាពលរដ្ឋមានការពិបាកយល់។

១.២.៥ ការរៀបចំថវិកានៅថ្នាក់ក្រោមជាតិមិនទាន់បានគិតគូឱ្យបានគ្រប់ជ្រុងជ្រោយ ជាពិសេសមិនសូវបានផ្តោតលើបញ្ហាស្ត្រី និងកុមារ។

១.២.៦ រាជរដ្ឋាភិបាល មានយន្តការសម្រាប់លើកកម្ពស់ឱ្យមានការចូលរួមរបស់ ប្រជាពលរដ្ឋ ក្នុងដំណើការរៀបចំថវិកាតែប្រជាពលរដ្ឋភាគ ច្រើនខ្វះព័ត៌មាន ក្នុងការចូលរួម ឬពេល ខ្លះពួក គាត់បានចូលរួមដែរ តែរាល់សំណើដែល ពួកគាត់បានលើកមិនត្រូវបានគេយកមកពិចារណា។

១.២.៧ រដ្ឋសភាពតែងតែផ្តល់ឱកាសចំពោះការចូលរួមពីស្ថាប័នពាក់ព័ន្ធ តែការចូលរួមនោះហាក់មិនទាន់មានអត្ថន័យពេញលេញនៅឡើយ ដោយសារតែកន្លងមកមិនដែលបានឆ្លុះបញ្ចាំងជាមួយនឹងអ្វី ដែលប្រជាជនបានលើកឡើង និងតម្រូវការអ្វីដែលរដ្ឋាភិបាលផ្តល់ឱ្យ។

## ១.៣. សំណូមពរនិងអនុសាសន៍លើទិសដៅជាអាទិភាពដែលត្រូវអនុវត្តបន្តដោយភាគីពាក់ព័ន្ធនៃការចូលរួមរបស់សាធារណជនក្នុងដំណើរការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ(១១ ចំណុច)៖

១.៣.១ ស្នើឱ្យមានការបណ្តុះបណ្តាលអ្នកពាក់ព័ន្ធដើម្បីឱ្យពួកគេមាន ចំណេះដឹងគ្រប់គ្រាន់ដែលអាចឱ្យគេយល់បានពីតម្លៃ និងអត្ថប្រយោជន៍នៃការចូលរួមក្នុងដំណើរការរៀបចំថវិកា។

១.៣.២ ស្នើឱ្យរដ្ឋសភាធ្វើការសម្របសម្រួលក្នុងការត្រួតពិនិត្យ និងសួរដេញដោល ដល់ក្រសួងពាក់ព័ន្ធទាក់ទងនិងដំណើការចំណាយនានា និងចាក់ផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយ។

១.៣.៣ បើកចំហរឱ្យមានការចូលរួមក្នុងការចូលរួមពីអង្គការសង្គមស៊ីវិល សារព័ត៌មាន ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធផ្សេងៗទៀត ក្នុងដំណាក់ការកសាង និងអនុវត្តថវិកា។

១.៣.៤ ស្នើឱ្យមានការរៀបចំវេទិកាសាធារណៈដោយលើកទឹកចិត្តឱ្យមានការចូលរួមពីប្រជាពលរដ្ឋ សង្គមស៊ីវិល វិស័យឯកជន យុវជន និងជនជាតិដើមភាគតិច។

១.៣.៥ ស្នើឱ្យមានការបញ្ជាក់នូវអំណាចរបស់រដ្ឋសភា និង ព្រឹទ្ធសភាដែលជាតំណាងរបស់ប្រជាពលរដ្ឋក្នុងក្រមខ័ណ្ឌ ច្បាប់ពាក់ព័ន្ធការរៀបចំយន្តការរបស់ខ្លួនក្នុងដំណើរកសាង អនុវត្ត និងត្រួតពិនិត្យថវិកា។

១.៣.៦ ស្នើឱ្យមានការរៀបចំព័ត៌មានថវិកាសម្រាប់ប្រជាពលរដ្ឋ ឱ្យមានលក្ខណៈសាមញ្ញងាយយល់ព្រមទាំងដាក់ សេចក្តីលម្អិតនៃថវិកាជាតិនៅលើគេហទំព័រនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

១.៣.៧ ស្នើសុំឱ្យមានភាពជាដៃគូជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងផ្សេងទៀតៗក្នុងដំណើរលទ្ធកម្មសាធារណ និងបង្កើនតម្លាភាពក្នុងការចំណាយជាសាធារណៈ។

១.៣.៨ ស្នើឱ្យដាក់បញ្ចូលធាតុចូលជាពិសេសផ្តោតលើការចូលជាសាធារណៈរបស់ប្រជាពលរដ្ឋ និងបង្កើនតម្លាភាពក្នុងច្បាប់ថ្មីស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដែលគ្រោងនឹងអនុម័តនាពេលខាងមុខ។

១.៣.៩ បង្កើនការយល់ដឹង និងលើកកម្ពស់ការចូលរួមរបស់សាធារណជនទៅលើតម្លាភាព និងគណនេយ្យភាពថវិការួមទាំងដំណើរការនៃការរៀបចំផែនការថវិកា និងការអនុវត្តផែនការថវិកា នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

១.៣.១០ សម្របសម្រួលឱ្យមានយន្តការ និងនីតិវិធី ឬការណែនាំជាលក្ខណៈប្រព័ន្ធដែលអាចបង្ករភាពងាយស្រួល ដល់ការចូលរួមនិងត្រួតពិនិត្យតាមដានរបស់សាធារណៈជនក៏ដូចជាអង្គការសង្គមស៊ីវិលនានា

១.៣.១១ ធានាឱ្យមានយន្តការទទួលបានទិន្នន័យនិងព័ត៌មានត្រឡប់ជាផ្លូវការពីក្រសួងស្ថាប័នពាក់ព័ន្ធ ក៏ដូចជាយន្តការប្រមូលធាតុចូលពីសាធារណៈជន ដើម្បីលើកកម្ពស់ការចូលរួមទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

## ២.១. ចំណុចវិជ្ជមាននៃយន្តការដែលមានស្រាប់ និងការចូលរួមរបស់សាធារណជន ក្នុងដំណើរការកសាងផែនការរៀបចំថវិកា និងការត្រួតពិនិត្យតាមដានការអនុវត្តផែនការថវិការដ្ឋបាលថ្នាក់ក្រោមជាតិ (១០ ចំណុច)៖

២.១.១ មានលិខិតបទដ្ឋានគតិយុត្តិសំខាន់ៗដូចជា៖១) អនុក្រិត្យលេខ២៦ អនក្រ.បកចុះថ្ងៃទី ២០ មេសា ឆ្នាំ២០២២ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំសង្កាត់ (មាត្រា១២) ។២)ប្រកាសលេខ ៣៣១ ស.ហ.វ-ប្រក ស្តីពីការរៀបចំការអនុវត្តថវិកាឃុំសង្កាត់ ៣)មានសេចក្តីណែនាំលេខ ០២៥.ស.ណ.ន ចុះថ្ងៃទី៨ ខែមិថុនាឆ្នាំ ២០២១ ៤) មានប្រតិទិន និងជំហាននៃការអនុវត្ត ៥) ការផ្សព្វផ្សាយ និងពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ និង ៦) យន្តការគាំទ្រ និងត្រួតពិនិត្យ។

២.១.២ មានការផ្សព្វផ្សាយពីថវិកាយ៉ាងហោចណាស់ពីរសប្តាហ៍មុនដល់ប្រជាពលរដ្ឋនៅសហគមន៍។

២.១.៣ មានការរៀបចំអង្គប្រជុំរបស់គណៈកម្មការកសាងផែនការជាប្រចាំ។

២.១.៤ មានសេចក្តីណែនាំ របស់ឃុំសង្កាត់ក្នុងការជូនដំណឹងដល់ប្រជាពលរដ្ឋក្នុងការអនុម័តថវិកា។

២.១.៥ មានណែនាំច្បាស់ពីជំហានក្នុងការបំពេញទម្រង់ថវិកាសង្ខេប

២.១.៦ មានយន្តការត្រួតពិនិត្យ និងតាមដានការចំណាយថវិកានៅថ្នាក់ក្រោមជាតិ។

២.១.៧ មានសេចក្តីណែនាំស្តីពីការផ្សព្វផ្សាយលេខ ០២៥ និងបានផ្សព្វផ្សាយនៅតាមបណ្តាខេត្តមួយចំនួន ឧទាហរណ៍ខេត្តស្វាយរៀង ដែលសេចក្តីណែនាំនោះផ្តោតលើ៧ ជំហាន និងបានអញ្ជើញប្រជាពលរដ្ឋមកប្រជុំក្នុងអំឡុងពេលខែតុលា។

២.១.៨ អង្គការមួយចំនួនបានជួយសម្របសម្រួលក្នុងការអនុវត្តគម្រោងគណនេយ្យភាពសង្គម។

២.១.៩ តាមរយៈការប្រមូលទិន្នន័យដោយអង្គការវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API) ទិន្នន័យថវិកាហាក់ងើបឡើងបន្តិចវិញបន្ទាប់ការថមថយនៃជំងឺកូវីដ១៩។

២.១.១០ ការរៀបចំថវិកា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានយន្តការច្បាស់លាស់ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

## ២.២. បញ្ហាប្រឈមមួយចំនួនដែលរាំងស្ទះដល់ដំណើរការចូលរួមរបស់សាធារណជន ក្នុងដំណើរការកសាងផែនការរៀបចំថវិកា និងការត្រួតពិនិត្យតាមដានការអនុវត្តផែនការថវិកា រដ្ឋបាលថ្នាក់ក្រោម ជាតិ (៩ ចំណុច)៖

២.២.១ មានការលំបាកក្នុងការបិទផ្សាយនៅតាមមន្ទីរពេទ្យ និងនៅតាមសាលារៀនទាក់ទងនឹងការអនុវត្តក្របខ័ណ្ឌគណនេយ្យភាពសង្គម (ISAF)

២.២.២ ថវិកាបម្រុងនឹងឡើងនៅថ្នាក់ក្រោមជាតិ មានការធ្លាក់ចុះដោយសាតែការរាតត្បាតនៃជំងឺកូវីដ-១៩។

២.២.៣ ការយល់ដឹងរបស់អាជ្ញាធរថ្នាក់ក្រោមជាតិក្នុងការរៀបចំថវិកានៅមានកម្រិតនៅឡើយដោយភាគច្រើនមិនសូវបានអនុវត្តទៅតាមសេចក្តីណែនាំដែលមានចែងក្នុងបទដ្ឋានគតិយុត្តិ។

២.២.៤ យន្តការសម្របសម្រួលផ្សព្វផ្សាយនៅថ្នាក់ក្រោមជាតិនៅខ្វះនៅឡើយ ដោយហេតុថាកន្លងមកនៅតាមឃុំនីមួយៗ អាជ្ញាធរមិនសូវមានគំនិតក្នុងស្វែងរកយុទ្ធសាស្ត្រថ្មីក្នុងការផ្សព្វផ្សាយ ដោយកន្លងមកអនុវត្តតែតាមរបៀបដដែលៗ។

២.២.៥ អាជ្ញាធរឃុំខ្លះខ្វះវិធីសាស្ត្រក្នុងការកៀគរពលរដ្ឋដើម្បីឱ្យគាត់ចូលរួមក្នុងដំណើរការរៀបចំថវិកា។ ប្រជាពលរដ្ឋខ្លះមិនបានចូលរួមដោយសារគាត់គិតថាការលើកឡើងរបស់គាត់មិនដែលបានឆ្លើយតប។

២.២.៦ ការចំណាយនៅថ្នាក់ក្រោមជាតិ ភាគច្រើននៅតែផ្តោតលើហេដ្ឋារចនាសម្ព័ន្ធ ខណៈដែលការវិភាជផ្តោតលើបញ្ហាសង្គមនៅមានលក្ខណៈតិចតួចនៅឡើយ។

២.២.៧ ការផ្សព្វផ្សាយពីថវិកានៅថ្នាក់ឃុំមិនទាន់បានទូលំទូលាយ លើកលែងតែឃុំដែលមានការគាំទ្រដោយអង្គការសង្គមស៊ីវិល។

២.២.៨ ការចូលរួមរបស់យុវជននៅមានលក្ខណៈតិចតួចនៅឡើយ។ តាមការអង្កេតរបស់របស់អង្គការ យូនីសេហ្វ (UNICEF) បានបង្ហាញថាយុវជនបានចូលរួមប្រមាណជា៥%ប៉ុណ្ណោះ។

២.២.៩ សវនកម្មឃុំសង្កាត់មានលក្ខណៈមិនទាន់ច្បាស់លាស់នៅឡើយ លើស្ថាប័នដែលអនុវត្ត។

## ២.៣. សំណូមពរ និងអនុសាសន៍លើទិសដៅជាអាទិភាព ដែលត្រូវអនុវត្តបន្តដោយភាគីពាក់ព័ន្ធក្នុងការចូលរួមរបស់សាធារណជនក្នុងដំណើរការកសាងផែនការរៀបចំថវិកា និងការត្រួតពិនិត្យ តាមដានការអនុវត្តវដ្ត ផែនការថវិការដ្ឋបាលថ្នាក់ក្រោមជាតិ (៧)៖

២.៣.១ ស្នើឱ្យរាជរដ្ឋបាលភិបាលបង្កើនការវិភាជថវិកានៅថ្នាក់ក្រោមជាតិនិងផ្តោតលើការផ្តោតលើការអភិវឌ្ឍសង្គមឱ្យបានច្រើនយ៉ាងតិច ៥ ភាគរយ នៃថវិកាជាតិ។

២.៣.២ លើកកម្ពស់ឱ្យមានការចូលរួមពីយុវជនឱ្យបានច្រើនដោយហេតុថាចំនួនយុវជននៅក្នុងប្រទេសកម្ពុជាមានចំនួនច្រើនតែការចូលរួមកន្លងមកមានលក្ខណៈតិចតួចនៅឡើយ។

២.៣.៣ ស្នើឱ្យរាជរដ្ឋាភិបាលជួយអញ្ជើញសហគមន៍បានចូលរួមប្រជុំអណត្តិជាមួយឃុំ ដើម្បីចែករំលែកព័ត៌មាន។

២.៣.៤ ស្នើឱ្យមានការពង្រឹងពីតួនាទីរបស់ឃុំក្នុងការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ហើយជំរុញប្រជាពលរដ្ឋឱ្យសកម្មក្នុងការចូលរួមអភិវឌ្ឍន៍ក្នុងសហគមន៍។

២.៣.៥ ស្នើឱ្យរាជរដ្ឋាភិបាលជួយ ពន្លឿនក្នុងការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន។

២.៣.៦ ស្នើឱ្យពិនិត្យលើសវនកម្មនៅកម្រិតឃុំ/សង្កាត់ និងកំណត់ឱ្យបានច្បាស់លើស្ថាប័នដែលអនុវត្ត។

២.៣.៧ ស្នើបង្កើនការវិភាជថវិកាផ្តោតលើការអភិវឌ្ឍសង្គមនៅថ្នាក់ក្រោមជាតិ និងរៀបចំយន្តការអនុវត្តឱ្យមានប្រសិទ្ធភាព។

## ៣.១. ចំណុចវិជ្ជមាននៃយន្តការដែលមានស្រាប់ទាក់ទងនឹងការរៀបចំថវិកាឆ្លើយតបទៅនឹងការគ្រប់គ្រងធនធានធម្មជាតិ សហគមន៍មូលដ្ឋានការប្រែប្រួលអាកាសធាតុ (១៣ ចំណុច)៖

៣.១.១ រាជរដ្ឋាភិបាលមានយន្តការ ក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុដោយបានចាត់ទុកថា បញ្ហានៃការប្រែប្រួលអាកាសធាតុជាបញ្ហារួមដែលក្នុងក្នុងនោះតាមក្រសួងនីមួយៗសុទ្ធតែបានគិតគូ លើការបញ្ជ្រាបលើការប្រែប្រួលអាកាសធាតុដោយបញ្ហានៃការប្រែប្រួលអាកាសធាតុ ក៏ត្រូវដាក់បញ្ចូលទៅក្នុងយុទ្ធសាស្ត្រចតុកោណក្នុងដំណាក់កាលទី៤។

៣.១.២ ក្រសួងបរិស្ថាន បានសម្របសម្រួលអន្តរក្រសួង ក្នុងការបង្កើតក្រុមការងារបច្ចេកទេសផ្តោតលើការប្រែប្រួលអាកាសធាតុហើយតែងតែបានប្រជុំជាប្រចាំ។

៣.១.៣ រហូតមកដល់ពេលនេះកម្ពុជាអាចជាប្រទេសមួយដែលអាចមានលទ្ធភាពក្នុងការលក់ឥណទានកាបូន ហើយថវិកាដែលទទួលបានពីលក់កាបូន ត្រូវបានយកទៅប្រើប្រាស់ក្នុងការបង្កើនជីវភាពរបស់ប្រជាពលរដ្ឋនៅសហគមន៍។

៣.១.៤ ក្រសួងបរិស្ថានបាននិងកំពុងគិតគូផ្តល់ថវិកាដែលទទួលបានពីឥណទានកាបូនដល់ ថ្នាក់ក្រោមជាតិ

៣.១.៥ រដ្ឋាភិបាលបាននិង កំពុងគិតគូឱ្យសហគមន៍ បានចូលរួមក្នុងវេទិកាទាក់ទងនឹងការប្រែប្រួលអាកាសធាតុនៅកម្រិតអន្តរជាតិ។

៣.១.៦ កម្ពុជាបាននិងកំពុងគិតគូដល់មូលនិធិបៃតង (Green Fund)

៣.១.៧ ថវិការបស់ក្រសួងបរិស្ថានមានការកើនឡើងដែលបានផ្តោតលើវិស័យបរិស្ថានជាពិសេសការប្រែប្រួលអាកាសធាតុ។

៣.១.៨ ក្រសួងអភិវឌ្ឍន៍ជនបទបានបង្កើតគោលនយោបាយលើកកម្ពស់គុណភាព និងគុណតម្លៃដោយផ្តោតលើកម្មវិធីទាំង៤ដោយផ្តោតលើការបង្កើនប្រាក់ចំណូលរបស់ប្រជាពលរដ្ឋ ផែនការថវិកាកម្មវិធី កម្មវិធីហេដ្ឋារចនាសម្ព័ន្ធ និងការប្រែប្រួលអាកាសធាតុ។

៣.១.៩ ក្រសួងអភិវឌ្ឍន៍ជនបទបានបង្កើតគោលនយោបាយ ២០២១-២០៣០។ ក្នុងនោះផងដែរ ក្រសួងអភិវឌ្ឍន៍ជនបទ តែងតែបានយកចិត្តទុកដាក់ផងដែរ លើហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទឱ្យនៅមានភាពរឹងមាំ និងធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ហើយទន្ទឹមគ្នានោះជួយការពារផងដែរ ដល់ប្រជាជនងាយរងគ្រោះពីហេតុការណ៍គ្រោះធម្មជាតិ។

៣.១.១០ ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម ដែលជាសេនាធិការរបស់ក្រសួងកសិកម្ម ក៏បានគិតគូរក្នុងការផ្តល់ឥណទានកាបូនផងដែរ។

៣.១.១១ រាជរដ្ឋាភិបាលថ្មីៗនេះបានគិតគូ និងបានធ្វើចំណាត់ការដកហូតដីព្រៃលិចទឹក មកវិញពីអ្នកកាន់កាប់ខុសច្បាប់។

៣.១.១២ កម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC)

៣.១.១៣ រាជរដ្ឋាភិបាលកម្ពុជាមានផែនការយុទ្ធសាស្ត្រការប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣ (CCCSP)

## ៣.២. បញ្ហាប្រឈមមួយចំនួនដែលរាំងស្ទះដល់ដំណើរការអនុវត្តកន្លងមកការរៀបចំថវិកាឆ្លើយតបទៅនឹងការ គ្រប់គ្រងធនធានធម្មជាតិ សហគមន៍មូលដ្ឋាន ការប្រែប្រួលអាកាសធាតុ(៧ ចំណុច)៖

៣.២.១ ខ្វះសេវាមូលដ្ឋាន ផ្តោតលើទឹកស្អាត ខ្វះឥណទាន និងខ្វះព័ត៌មានក្នុងការយល់ដឹង

៣.២.២ ការប្រែប្រួលអាកាសធាតុខុសពីប្រក្រតីដែលបង្កឱ្យខ្យល់ព្យុះ ខ្យល់កន្ត្រាក់ទឹកជំនន់ ដែលបានបង្ករគ្រោះមហន្តរាយជារៀងរាល់ឆ្នាំដែលធ្វើឱ្យរាជរដ្ឋាភិបាលចំណាយថវិកាជាច្រើនក្នុងការស្តារឡើងវិញ។

៣.២.៣ ខ្វះការឧបត្ថម្ភធានពីដៃគូរអភិវឌ្ឍន៍ និងខ្វះភាពជាម្ចាស់

៣.២.៤ ប្រព័ន្ធអេកូឡូស៊ី និងរបបទឹក ដែលកត្តានេះប៉ះពាល់ច្រើនដល់ជីវចម្រុះ ជាពិសេសប្រព័ន្ធអេកូឡូស៊ីនៅតំបន់ទន្លេមេង្គង និងតំបន់ឆ្នេរ។

៣.២.៥ ការនេសាទហួសកម្រិត ដែលធ្វើឱ្យប៉ះពាល់ដល់ធនធានជលផល។

៣.២.៦ ខ្វះថវិកានៅកម្រិតឃុំសង្កាត់ ផ្តោតលើការគ្រប់គ្រងធនធានធម្មជាតិ និងបម្រែបម្រួលអាកាសធាតុ។

៣.២.៧ ទិន្នន័យទាក់ទងនឹងការប្រែប្រួលអាកាសធាតុនៅមានកម្រិត និងអ្នកចូលរួមក៏នៅមានកម្រិតផងដែរ។

## ៣.៣. សំណូមពរ និងអនុសាសន៍លើទិសដៅជាអាទិភាពដែលត្រូវ អនុវត្តបន្តដោយ ភាគីពាក់ព័ន្ធ នៃការរៀបចំថវិកាឆ្លើយតបទៅនឹងការគ្រប់គ្រងធនធានធម្មជាតិ សហគមន៍មូលដ្ឋាន ការប្រែប្រួលអាកាសធាតុ (៥ ចំណុច)៖

៣.៣.១ ស្នើផ្តោតលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធធន់នឹងការប្រែប្រួលអាកាសធាតុ។

៣.៣.២ ស្នើឱ្យផ្តល់ហរិញ្ញប្បទានបៃតង ក្នុងករណីដែលថ្នាក់ក្រោមជាតិ ឬសហគមន៍ត្រូវការ

៣.២.៣ ស្នើវិភាជថវិកា១០ ភាគរយ នៃថវិកាឃុំសង្កាត់ផ្តោតលើការអភិរក្សធនធានធម្មជាតិជាពិសេសធនធានជលផល។

៣.២.៤ ស្នើឱ្យរដ្ឋាភិបាលគិតគូក្នុងការផ្តល់ទិន្នន័យលើការវិភាជន៍ថវិកាឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ

៣.២.៥ ស្នើឱ្យបង្ហាញទិន្នន័យនៃថវិកាទទួលបានពីការលក់កាបូនដល់សាធារណៈជន។

ជាចុងបញ្ចប់ យើងទាំងអស់គ្នាដែលជាអ្នកចូលរួមនៅក្នុងវេទិកានេះ សូមសម្តែងនូវការប្តេជ្ញាចិត្ត បន្តធ្វើការរួមគ្នាក្នុងភាពជាដៃគូប្រកបដោយវិជ្ជាជីវៈ និងប្រកបដោយបរិយាកាសអំណោយផលដើម្បីលើកកម្ពស់តម្លាភាព និងគណនេយ្យ ភាពក្នុងការរៀបចំថវិកា និងការត្រួតពិនិត្យតាមដាន ជាពិសេសនៅថ្នាក់ក្រោមជាតិ។